# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់រៀបចំការអភិវឌ្ឍតំបន់តាថាវ និងប្រាសាទព្រះវិហារ នៃខេត្តព្រះវិហារ

~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /១១៩៨/៧១ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /០៣០៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- តាមស្មារតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីចំរុះកម្ពុជា-ថៃ នៅខេត្តសៀមរាប និងខេត្តឧប៉ុនរាជធានី កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣
- តាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ សំរាប់រៀបចំការអភិវឌ្ឍ តំបន់តាថាវ និងប្រាសាទព្រះវិហារ នៃខេត្តព្រះវិហារ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២-ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៣-ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
~~~~~~~~

៤-ឯកឧត្តម **ទាន់ សាផាន់** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៥-ឯកឧត្តម **ឌី យ៉ាទ** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦-ឯកឧត្តម **ទ៉ា គីមហុង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន សមាជិក

៧-ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-ឯកឧត្តម **យឹម សារិន្ទ** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៩-ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០- ឯកឧត្តម **ទីយ វឿន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល សមាជិក

១១- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈុំ សុជាតិ** នាយរងសេនាធិការចំរុះ និងជានាយកទីចាត់ការព្រំដែន នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

១២- ឯកឧត្តម **ព្រាប តាន់** អភិបាលខេត្តព្រះវិហារ សមាជិក

១៣- លោកឧត្តមសេនីយ៍ទោ **ជុំ ហាក់** នាយរងសេនាធិការ និងជាប្រធានការិយាល័យទី២ នៃកងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

១៤- លោកឧត្តមសេនីយ៍ត្រី **មៀច សុផាណា** ប្រធាននាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៥- លោក **សួស យ៉ារ៉ា** នៅអាជ្ញាធរទេសចរណ៍កម្ពុជា សមាជិក

**ប្រការ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ច :

- សិក្សាស្រាវជ្រាវ រៀបចំចងក្រង និងកសាងប្លង់មេ សំរាប់អភិវឌ្ឍន៍តំបន់តាថាវ និងប្រាសាទព្រះវិហារ ជាអាទិ៍ការកំណត់តំបន់នានាមាន ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ អគ្គិសនី ទឹកស្អាត តំបន់ដីលំនៅដ្ឋាន ទីផ្សារលក់ដូរ ប្រព័ន្ធលូទឹក ការការពារបរិស្ថាន សាលារៀន មណ្ឌលសុខភាព មន្ទីរពេទ្យ ដីបំរុងអភិវឌ្ឍន៍សេដ្ឋកិច្ច ដីកសិកម្ម និងដីត្រៀមបំរុងសំរាប់សាងសង់សណ្ឋាគារ ផ្ទះសំណាក់ កន្លែងកំសាន្តនានា រួចសុំការសំរេចពីរាជរដ្ឋាភិបាល
- សហប្រតិបត្តិការជាមួយភាគីថៃ ដើម្បីពិភាក្សាឯកភាពលើគំរោងប្លង់មេ សំរាប់អភិវឌ្ឍន៍តំបន់តាថាវ និងប្រាសាទព្រះវិហារ ជាតំបន់ទេសចរណ៍ វប្បធម៌ និងធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយវិនិយោគិនក្នុង និងក្រៅប្រទេស ដើម្បីធ្វើការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនានា នៅតំបន់តាថាវ និងប្រាសាទព្រះវិហារ ឱ្យបានស្របតាមគំរោងប្លង់មេ ដែលប្រមុខរាជរដ្ឋាភិបាលបានសំរេច

- កសាងផែនការសកម្មភាពសំរាប់វិនិយោគសាធារណៈ និងទាក់ទាញវិនិយោគឯកជន ដើម្បីជំរុញល្បឿន នៃការអភិវឌ្ឍតំបន់តាថាវ និងប្រាសាទព្រះវិហារ
- សហការជាមួយសហគមន៍អន្តរជាតិ ដើម្បីកៀរគរសុំជំនួយហិរញ្ញប្បទាន ក្នុងការវិនិយោគសាធារណៈសំខាន់ៗ នៅតំបន់តាថាវ និងប្រាសាទព្រះវិហារ
- អនុវត្តការងារឱ្យបានស្របតាមកិច្ចព្រមព្រៀងអន្តរជាតិដែលនៅជាធរមាន អនុស្សរណៈទ្វេភាគីកម្ពុជា- ថៃ និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារតាមជំហានៗ ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។

**ប្រការ៣ :** - រាល់ការអនុវត្តភារកិច្ចក្នុងប្រការ២ខាងលើនេះ ពុំមានផលប៉ះពាល់ដល់ការកំណត់ខ្សែព្រំដែន និងខ័ណ្ឌសីមា រវាងកម្ពុជា និងថៃ នៅតំបន់នោះទេ ។

**ប្រការ៤ :** - សមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំ និងទទួលភារកិច្ចតាមការកំណត់របស់ប្រធាន
- ប្រធានគណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ៥ :** - គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយសំរាប់ជំនួយការ ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងមានសិទ្ធិប្រើប្រាស់ត្រា និងថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តព្រះវិហារ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ